**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**

**សភាព្រហ្មទណ្ឌ**
សំណុំរឿងព្រហ្មទណ្ឌ
លេខ ១៩៩
ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩
សាលដីកា
លេខ ២៧ "II"
ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០

# សាលដីកា

## តាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០
ដោយអង្គជំនុំជម្រះមានសមាសភាពចៅក្រមដូចខាងក្រោម ៖

១. លោកស្រី [redacted] ជាប្រធាន
២. លោក [redacted] ជាចៅក្រម
៣. លោក [redacted] ជាចៅក្រម
៤. លោក [redacted] ជាចៅក្រម
៥. លោកស្រី [redacted] ជាចៅក្រម

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

**តំណាងមហាអយ្យការ**

លោក [redacted] ឋានៈជាព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ១៥៣ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់ជនជាប់ចោទឈ្មោះ [redacted] ឧត្តម ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៥៣ ក្រV "ស.ស" ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ដែលមាន ៖

**- ជនជាប់ចោទ ៖**

១-ឈ្មោះ [redacted] ឧត្តម ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ មុខរបរ កម្មករសំណង់ ទីលំនៅមុន [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ប្រពន្ធឈ្មោះ [redacted] មានកូន០២នាក់ ជានីតិជន ទោសពីមុនគ្មាន ។ (ក្នុងឃុំ) (អ្នកប្តឹងសាទុក្ខ)

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខៈ ១៩៧៦ ដ.ឃ.ដ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨



Scanned with CamScanner

-មានលោកស្រី [redacted] សុវ៉ែន ជាមេធាវីការពារ

២-ឈ្មោះ [redacted] លាង ហៅ កូកា ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ មុខរបរបើកហាងម៉ាស្សា ទីលំនៅមុនពេលឃុំខ្លួន [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] "រ" កូនគ្មាន ជានីតិជន ទោសពីមុនគ្មាន ។ (ក្នុងឃុំ) (មិនប្តឹងសាទុក្ខ)

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខៈ ១៩៧៧ ដ.ឃ.ជ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨

៣-ឈ្មោះ [redacted] ចាន់ដារ៉ា ហៅ ផល ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ មុខរបរ មិនពិតប្រាកដ ទីលំនៅមុនពេលឃុំខ្លួន [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ជានីតិជន ទោសពីមុនគ្មាន ។ (ក្នុងឃុំ) (មិនប្តឹងសាទុក្ខ)

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខៈ ១៩៧៨ ដ.ឃ.ជ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨

- **ជាប់ចោទពីបទ** ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៨ វេលាម៉ោង ១២ និង ០០នាទី កម្លាំងសមត្ថកិច្ច នៃមន្ទីរប្រឆាំងគ្រឿងញៀនបានចុះអនុវត្តវិធានញុះញង់ នៅចំណុចបន្ទប់ជួលលេខ៦០១ ផ្លូវ៥៣ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ បានឃាត់ខ្លួនជនជាប់ចោទ០២នាក់ គឺឈ្មោះ [redacted] ចាន់ដារ៉ា ហៅ ផល ភេទប្រុស អាយុ៣៦ឆ្នាំ និងឈ្មោះ [redacted] ឧត្តម ភេទប្រុស អាយុ ៣១ឆ្នាំ ខណៈពេល ជានជាប់ចោទកំពុងតែធ្វើសកម្មភាពជួញដូរគ្រឿងញៀន ហើយសមត្ថកិច្ចបានធ្វើការដកហូតគ្រឿងញៀនជាប្រភេទ មេតំហ្វេតាមីន (ICE) សរុបទម្ងន់ ២,៧៥ក្រាម ។ ក្រោយពីបានធ្វើការសាក សួរឬចមកឈ្មោះ [redacted] ចាន់ដារ៉ា ហៅ ផល បានឆ្លើយសារភាពថាៈ គ្រឿងញៀនដែលសមត្ថកិច្ចដក ហូតបានពីខ្លួននោះ គឺខ្លួនទិញពីឈ្មោះ [redacted] លាង ហៅ កូកា ដើម្បីយកទៅលក់បន្ត ហើយកន្លងមកខ្លួនក៏ធ្លាប់បានទិញពីឈ្មោះ ទ្រី ភេទប្រុស អាយុប្រហែល២៥ឆ្នាំ ។ ចំពោះជនជាប់ចោទឈ្មោះ [redacted] លាង ហៅ កូកា ដែលសមត្ថកិច្ចឃាត់ខ្លួននៅចំណុចមុខភោជនីយដ្ឋាន ឈៀ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ បានឆ្លើយសារភាពថាៈ ខ្លួនទិញគ្រឿងញៀនពីឈ្មោះ ក្តី ភេទប្រុស អាយុប្រហែល២៦ឆ្នាំ ហើយយកមកលក់ឱ្យឈ្មោះ [redacted] ចាន់ដារ៉ា ហៅ ផល ។

សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ៣៤៣៥ "អ" ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ ៖

១.ផ្តន្ទាទោសលើ៖



Scanned with CamScanner

ក/ឈ្មោះ [redacted]ចាន់ដារ៉ា ហៅ ផល ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ

ខ/ឈ្មោះ [redacted]ឧត្តម ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ

គ/ឈ្មោះ [redacted]លាង ហៅ កូកា ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ

ដាក់ពន្ធនាគារកំណត់ក្នុងម្នាក់ៗ ០៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ក្នុងម្នាក់ចំនួន ៦,០០០,០០០៛ (ប្រាំមួយលាន) រៀល ដាក់ចូលថវិកាជាតិ ។

ពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-តាមមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន វត្ថុដែលចាប់យករួមមាន៖

-ស្រោមសំបុត្រពណ៌គគីរ មានក្រាមពណ៌ថ្លាទម្ងន់ ២,៧៥ (ពីរក្បៀសចិតសិបប្រាំ) ក្រាម ត្រូវរឹបអូសបំផ្លាញចោល ។

ចំពោះទូរស័ព្ទដៃចំនួន ០៣គ្រឿង ម៉ាកណូគាចុចពិលពណ៌ខៀវចំនួន០២គ្រឿង និងពណ៌ខ្មៅចំនួន០១គ្រឿង ត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ ។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទ ឈ្មោះ [redacted]ចាន់ដារ៉ា ហៅ ផល ,[redacted]ឧត្តម និងឈ្មោះ [redacted] លាង ហៅ កូកា និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ ។

ទុក្ខសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់ ។

សាលក្រមនេះត្រូវបានឈ្មោះ [redacted]ឧត្តម ប្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ ៨៣៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨ គ្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

សាលក្រមនេះត្រូវបានឈ្មោះ [redacted]លាង ប្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ ៨៣៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨ គ្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

សាលាឧទ្ធរណ៍បានសម្រេចតាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ៥៣ ក្រV "ស.ស" ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ ៖

ឆ្នាំ២០១៩ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ:

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ៨៣៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted]ឧត្តម ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ ៨៣៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted]លាង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

Scanned with CamScanner

៣-តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ ៣៤៣៥ "អ" ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូលដដែល ។

៤-បន្តការឃុំខ្លួនជនជាប់ចោទតាមនីតិវិធី ។

សាលដីកានេះជំនុំជម្រះ នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] លាង កំបាំងមុខជនជាប់ចោទឈ្មោះ ហេង ឧត្តម ។

-បើកសិទ្ធិប្ដឹងទាស់ និងប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

សាលដីកានេះត្រូវបានជនជាប់ចោទឈ្មោះ [redacted] ឧត្តម ប្ដឹងសាទុក្ខតាមបណ្ដឹងលេខ ១៥៣ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល។

**នាពេលសវនាការ**

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្ដីសន្និដ្ឋានថា តាមការពិនិត្យរឿងហេតុឃើញថា ការសម្រេចសេចក្ដីរបស់សាលាឧទ្ធរណ៍ដែលតម្កល់សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញទុកជាបានការដដែល គឺមានកស្ដុតាងនិងសំអាងហេតុត្រឹមត្រូវតាមច្បាប់ ព្រោះថា ជនជាប់ចោទឈ្មោះ [redacted] ឧត្តម ដែលជាម្ចាស់បណ្ដឹងសាទុក្ខបានឆ្លើយសារភាពអំពីសកម្មភាពរបស់ខ្លួន ក្នុងការចូលរួមប្រព្រឹត្តបទល្មើស ជាមួយបក្សពួកច្បាស់លាស់រួចហើយ ដូចមាននៅក្នុងសំអាងហេតុចំណុចទី៣ នៃសាលដីកាសាលាឧទ្ធរណ៍ស្រាប់។ម្យ៉ាងទៀត ជនជាប់ចោទ មិនបានដាក់សារណាការពារ បណ្ដឹងសាទុក្ខរបស់ខ្លួនទេ។ ដូច្នេះតំណាងមហាអយ្យការ ស្នើសុំប្រធានក្រុមប្រឹក្សាជំនុំជម្រះសម្រេច តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៥៣ ក្រV "ស.ស" ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល។

- ជនជាប់ចោទឈ្មោះ [redacted] ឧត្តម បានឆ្លើយថា ខ្លួនស្នើសុំឱ្យតុលាការកំពូលជួយបន្ធូរបន្ថយទោសឱ្យខ្លួនផង។

- លោកស្រីមេធាវី [redacted] សុវ៉ន បានធ្វើសេចក្ដីសន្និដ្ឋានថា ក្រោយពីបានសិក្សាលើសំណុំរឿង និងឆ្លងតាមការសួរដេញដោល របស់ប្រធានក្រុមប្រឹក្សានាពេលសវនាការរួចហើយមក យើងឃើញថា ជនជាប់ចោទគាត់បានទទួលស្គាល់កំហុស របស់គាត់ដែលបានប្រព្រឹត្ត ក៏ប៉ុន្តែគាត់មិនបានទទួលថាគាត់ជាអ្នកជួញដូរថ្នាំញៀន គាត់គ្រាន់តែទៅទិញថ្នាំញៀន ពីអ្នកលក់ដើម្បីយកមកចែកចាយឱ្យមិត្តភក្ដិនៅកន្លែងធ្វើសំណង់ ដោយសារគាត់មិនយល់អំពីពាក្យថា "ជួញដូរ" ការចែកចាយនៅក្នុងនិយមន័យនៃច្បាប់គឺជាការជួញដូរនេះឯង។ ជាក់ស្ដែងនៅពេលនេះ ជនជាប់ចោទឈ្មោះ [redacted] ឧត្តម គឺគាត់អត់បានយល់ថាអំពើរបស់គាត់ធ្វើគឺអំពើមួយដែលខុសច្បាប់ ដែលច្បាប់ចោទប្រកាន់ថា ជាអ្នកជួញដូរថ្នាំញៀន នោះទេ។

Scanned with CamScanner

ហេតុដូច្នេះ ខ្លួនស្នើសុំឱ្យប្រធានក្រុមប្រឹក្សា មេត្តាពិចារណាលើចម្លើយរបស់គាត់ដែលសុំបន្ធូរបន្ថយទោស និងសុំកុំលើកចំណុចសំណាងមកពិចារណាលើគាត់អី។

**តុលាការកំពូល**

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់អ្នកប្តឹងសាទុក្ខ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

**សំអាងហេតុ**

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៥៣ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ឧត្តម ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបាន តាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ឧត្តម បានទទួលស្គាល់ថាខ្លួនធ្លាប់ទំនាក់ទំនងទិញគ្រឿងញៀនយកទៅឱ្យម៉ូយ ចំនួន០៣លើក ក្នុងមួយលើកបានប្រាក់ ៣ម៉ឺនរៀល នៅថ្ងៃកើតហេតុឈ្មោះ [redacted] ចាន់ដារ៉ា ទូរសព្ទ័ឱ្យខ្លួនទៅទិញគ្រឿងញៀនយកទៅឱ្យម៉ូយរាល់ដង ក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនតែម្តង ម្យ៉ាងទៀតចម្លើយនេះស៊ីសង្វាក់ទៅនឹងភស្តុតាងដែលសមត្ថកិច្ចដកហូតបាន ដែលអាចបញ្ជាក់បានថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសពិតមែន។

៣-យល់ឃើញថា បណ្តឹងសាទុក្ខរបស់ជនជាប់ចោទ មិនមានមូលហេតុសមស្រប ដូចការកំណត់នៃមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ។

៤-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៥៣ ក្រV "ស.ស" ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ដែលសម្រេចមកនេះ ត្រឹមត្រូវហើយ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-បដិសេធបណ្តឹងសាទុក្ខលេខ ១៥៣ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៩ របស់ឈ្មោះ [redacted] ឧត្តម ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៥៣ ក្រV "ស.ស" ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការទាំងមូល។



Scanned with CamScanner

សាលដីកានេះ បានជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ និងប្រកាសសាលដីកាជាសាធារណៈនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០។

Scanned with CamScanner